**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

**លេខៈ** [illegible]

**រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៣**

# ប្រ កា ស

## ស្តីពី

## ការកំណត់និមិត្តសញ្ញាក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

---

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស.រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស.រកម ០១៩៦-០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- យោងស្មារតីទិវាវប្បធម៌ជាតិលើកទី ១ ០៣-មេសា-១៩៩៨

## សំ រេ ច

**ប្រការ១** : ត្រូវបានកំណត់និមិត្តសញ្ញាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយរូបព្រះកេសព្រះបាទជ័យវរ្ម័នទី ៧ ។

**ប្រការ២** : លក្ខណៈ និង អត្ថន័យរបស់និមិត្តសញ្ញាមាន :

- ព្រះកេសព្រះបាទជ័យវរ្ម័នទី ៧ ពណ៌ទឹកមាសស្រអាប់នៅចំកណ្តាលតំណាងឱ្យបញ្ញាញាណ ឧត្តមគតិ ភាពវៃឆ្លាត និងភាពទទួលខុសត្រូវក្នុងការដឹកនាំប្រទេសរបស់ថ្នាក់ដឹកនាំខ្មែរ
- កម្រងផ្កាឈូកទ្រព្រះកេសព្រះបាទជ័យវរ្ម័នទី ៧ ពណ៌ទឹកមាសថ្លា តំណាងឱ្យភាពល្អបរិសុទ្ធនៃព្រះពុទ្ធសាសនា រួមនិងការបង្កើតឡើងនូវលទ្ធិពុទ្ធរាជា ក្នុងការគ្រប់គ្រងប្រទេសរបស់វីរៈមហាក្សត្រខ្មែរ
- ផែនដីនៅពីក្រោមកម្រងផ្កាឈូករាងឆ្នូត ៤ ត្រឹមពាក់កណ្តាល ខាងក្រោមមានស្នាមអង្កាញ់ជាទឹករលកពណ៌ទឹកមាសស្រអាប់តំណាងឱ្យភពផែនដី និងធាតុទាំង៤ គឺ ទឹក ដី ភ្លើង ខ្យល់ ដែលជាលោកធាតុផ្តល់នូវកំណើតមនុស្ស និងធម្មជាតិ
- ត្រីសូលដែលនៅពីក្រោមជាប់និងផែនដីពណ៌ទឹកមាសស្រអាប់ផ្ទៃក្នុងថ្លា តំណាងឱ្យបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ និងតំណាងឱ្យព្រហ្មញ្ញសាសនា និងពុទ្ធសាសនាដែលស្ថិតនៅរួមជាមួយគ្នាក្នុងជំនឿរបស់ប្រជាជនកម្ពុជា
- ក្បាច់ផ្កាដូងដែលមានរាងជារង្វង់អមសងខាងរូបព្រះកេសព្រះបាទជ័យវរ្ម័នទី ៧ ពណ៌ទឹកមាសស្រអាប់ តំណាងឱ្យភោគផលកសិកម្មដ៏សំបូរហូរហៀរ ដែលសបញ្ជាក់ឱ្យឃើញនូវភាពឧស្សាហ៍ព្យាយាមរបស់បុព្វបុរសខ្មែរដែលបានកសាងទឹកដីឱ្យសម្បូររុងរឿង

- ពណ៌ទឹកមាសខ្ចី និងស្រអាប់ គឺតំណាងឱ្យសញ្ញាសង្គ្រោះដល់វប្បធម៌ អារ្យធម៌ខ្មែរ និងប្រជាពលរដ្ឋខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជា
- ឈ្មោះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនៅផ្ទៃខាងក្រោម ដោយមានពាក្យក្រសួងនៅចំកណ្តាលផ្ទៃទី ១ ហើយពាក្យវប្បធម៌ និងវិចិត្រសិល្បៈនៅផ្ទៃទី ២ អមសងខាងសរសេរជាអក្សរពណ៌ស្វៃ ដែលតំណាងឱ្យបរិស្ថានធម្មជាតិដ៏ស្រស់បំព្រងនៃទឹកដីកម្ពុជា រួមនិងក្តីសង្ឃឹមលើសាមគ្គីឯកភាពជាតិ របស់ប្រជាជនខ្មែរក្នុងការលើកស្ទួយវប្បធម៌ជាតិឱ្យរីកចំរើនខ្ពង់ខ្ពស់ឡើងវិញ ។

**ប្រការ៣** : និមិត្តសញ្ញានេះត្រូវបានកំណត់ឱ្យប្រើប្រាស់នៅលើ :

- លិខិតបទដ្ឋាន រដ្ឋបាល និងត្រាសំបុត្រ "ផ្លូវការ" របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- ប័ណ្ណសំគាល់ខ្លួនមន្ត្រីរាជការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- លិខិត ប័ណ្ណ ( សរសើរ ឬ កិត្តិយស ) របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- សញ្ញាប័ត្រ វិញ្ញាបនប័ត្រ លិខិតបញ្ជាក់ផ្សេងៗ ចេញដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- នាមប័ណ្ណរបស់ថ្នាក់ដឹកនាំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ( ចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើង ) ។

**ប្រការ៤** : មិនត្រូវបានអនុញ្ញាតឱ្យយកនិមិត្តសញ្ញានេះទៅប្រើប្រាស់ក្នុងលក្ខណៈក្រៅផ្លូវការ ឬឯកជន ខុសពីខ្លឹមសារដែលបានកំណត់ក្នុងប្រការ ៣ ។

**ប្រការ៥** : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អធិការដ្ឋាន គ្រប់អង្គភាពចំណុះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ចម្លងជូន** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  "ដើម្បីជ្រាបជាពត៌មាន"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

នរោត្តម - បុប្ផាទេវី